# អ្នកប្រើប្រាស់ទូរសព្ទមួយចំនួនបារម្ភពីការលួចថតសំឡេងសន្ទនាឯកជនមកផ្សព្វផ្សាយជាសាធារណៈ




បុរសម្នាក់កំពុងនិយាយទូរស័ព្ទនៅទីសាធារណៈមួយកន្លែងក្នុងរាជធានីភ្នំពេញ។ រូបថតនៅថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៣។ អាន វិចិត្រ/ ខេមបូចា

អ្នកប្រើប្រាស់ទូរសព្ទមួយចំនួនបារម្ភពីការលួចថតសំឡេងសន្ទនាជាលក្ខណៈឯកជន ក្រោយពីមានការបែកធ្លាយសំឡេងទំនាក់ទំនងជាលក្ខណៈឯកជនជាបន្តបន្ទាប់ហើយករណីខ្លះឈានដល់ការវាយប្រហារ ឬចោទប្រកាន់ផ្សេងៗ។

និស្សិតម្នាក់កំពុងសិក្សានៅរាជធានីភ្នំពេញលោក អេង នីន ឱ្យដឹងថា រូបលោកចាប់អារម្មណ៍ថា មានការលួចថតសំឡេងសន្ទនាឯកជនតាំងពីមានការផ្សព្វផ្សាយសំឡេងសន្ទនារវាងលោក កឹម សុខា និងនារីម្នាក់ឈ្មោះស្រីមុំ។ លោកបន្តថា ក្រោយមកក៏មានការបែកធ្លាយសំឡេងសន្ទនាជាលក្ខណៈឯកជនរបស់អ្នកផ្សេងៗទៀតក្រៅពីលោក កឹម សុខា ធ្វើឱ្យរូបលោកមានការព្រួយបារម្ភពេលនិយាយតាមទូរសព្ទម្តងៗ។

លោក អេង នីន លើកឡើងថា៖ «*វាប៉ះពាល់ឯកជនភាពរបស់យើង នៅពេលយើងនិយាយរឿងរ៉ាវអ៊ីចឹងទៅ យើងអត់ចង់ឱ្យអ្នកណាដឹង ដល់ពេលគេផ្សព្វផ្សាយឱ្យអ្នកផ្សេងដឹង ទី១ប៉ះពាល់ដល់កិត្តិយស។ មិនត្រឹមតែកិត្តិយសយើងទេ ពេលខ្លះវាប៉ះពាល់ដល់គ្រួសារ ឬដៃគូសន្ទនាជាមួយយើងផងដែរ*»។

សកម្មជនដីធ្លីម្នាក់នៅខេត្តត្បូងឃ្មុំ លោក ផុន សុផល ថ្លែងថា លោកខ្លាចក្នុងការនិយាយតាមទូរសព្ទ សូម្បីតែរឿងធម្មតា ឬដែលមិនមានអ្វីប្រឈមក៏ដោយ ព្រោះលោកមានអារម្មណ៍ថា ការនិយាយរបស់លោកមិនមានលក្ខណៈឯកជនគឺមានគេស្តាប់បានគ្រប់គ្នា។

លោក ផុន សុផល ឱ្យដឹងថា៖ «ការងារឯកជនភាពពេលខ្លះទំនាក់ទំនងស្នេហា ទំនាក់ទំនងអីផ្សេងក៏យកមកបែកធ្លាយដើម្បីកេងចំណេញដែរ។ យើងឃើញថា វាប្រឈមហានិភ័យខ្ពស់ចំពោះអ្នកប្រើប្រាស់ទូរសព្ទហ្នឹងសូម្បីតែនិយាយជាមួយបងក៏មានការបារម្ភដែរ»។

ប្រធានផ្នែកកម្មវិធីស្រាវជ្រាវ និងតស៊ូមតិនៃសមាគមបណ្ដាញយុវជនកម្ពុជា (CYN) លោក ហេង គឹមហុង សង្កេតឃើញថា ការបែកធ្លាយសំឡេងបន្តបន្ទាប់

បានធ្វើឱ្យលោកបារម្ភ និងមានអារម្មណ៍ថា មិនមានសុវត្ថិភាពពេលនិយាយតាមទូរសព្ទ។ លោកជំរុញឱ្យស្ថាប័នពាក់ព័ន្ធយកចិត្តទុកដាក់ក្នុងការរក្សាសុវត្ថិភាពដល់ការសន្ទនាជាលក្ខណៈឯកជនដែលច្បាប់ការពារ។

លោក ហេង គឹមហុង ថ្លែងថា៖ **«បើសិនជារឿងនេះមិនប៉ះពាល់ដល់សន្តិសុខជាតិ ឬ បង្កមហន្តរាយធ្ងន់ធ្ងរដល់ជាតិទេ ត្រូវរក្សាឯកជនភាពដល់ពលរដ្ឋ ឬ អតិថិជនទាំងអស់**»។

ការបែកធ្លាយសំឡេងសន្ទនាជាលក្ខណៈឯកជនបានផ្ទុះឡើងរវាងលោក កឹម សុខា និង ស្ត្រីម្នាក់ដែលអ្នកកាត់សក់ដែលគេស្គាល់ឈ្មោះថា ស្រីមុំ កាលពីឆ្នាំ២០១៦ ដែលពេលនោះមានការចាប់អារម្មណ៍ខ្លាំងពីមហាជន។ ក្រោយមកក៏មានការទម្លាយសារសំឡេងសន្ទនាជាលក្ខណៈឯកជនបន្តបន្ទាប់ដែរ។

នៅក្នុងដើមឆ្នាំ២០២៣នេះ មានការផ្សព្វផ្សាយសំឡេងទំនាក់ទំនងស្នេហាលាយលំពាក្យអាសអាភាសផងដែលមានការបញ្ជាក់ថា ជាអតីតអគ្គលេខាធិការបក្សភ្លើងទៀនលោក លី សុធារ៉ាយុទ្ធ។  ដោយឡែកនៅក្នុងខែមេសានេះ ក៏មានការបែកធ្លាយសំឡេងអភិបាលខេត្ត បាត់ដំបងលោក សុខ លូ និយាយគ្នាតាមទូរសព្ទវាយប្រហារទៅប្អូនស្រីបង្កើតលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន គឺលោកស្រី ហ៊ុន ស៊ីណាត ជុំវិញករណីអំពើពុករលួយនៅច្រកដូង។

ជុំវិញបញ្ហាព្រួយបារម្ភពីការលួចថតសំឡេងនិយាយគ្នាតាមទូរសព្ទនេះ អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជា លោក សុខ ឥសាន លើកឡើងថា ជាបញ្ហាតិចតួចមួយនៅកម្ពុជាមិនមានអ្វីគួរឱ្យព្រួយបារម្ភទេ។ លោកបន្តថា បើម្ចាស់ខ្លួនយល់ថា ខ្លួនរងគ្រោះពីការថតសំឡេងនេះអាចដាក់ពាក្យប្ដឹងទៅតុលាការ។

លោក សុខ ឥសាន្ត បន្ថែមថា៖ **«បើសិនជាសាមីជនយល់ថាការផ្សាយប៉ះពាល់អាចប្ដឹងទៅអង្គភាពសារព័ត៌មាន ឬ អ្នកផ្សព្វផ្សាយហ្នឹងឱ្យគេស្រាវជ្រាវទៅ»**។

ចំពោះសារព័ត៌មាន និងបណ្ដាញទំនាក់ទំនងសង្គមមួយចំនួនយកសំឡេងនេះយកទៅចុះផ្សាយនោះ លោក សុខ ឥសាន្ត ថ្លែងថា រដ្ឋាភិបាលមិនមានវិធានការទប់ស្កាត់ទេ គឺជាសេរីភាពសារព័ត៌មាន ។

ទោះជាលោក សុខ ឥសាន្ត លើកឡើងថា នេះជាបញ្ហាតូចមួយក៏ដោយ ក៏លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ថ្លែងនៅក្នុងខែមេសា ឆ្នាំ២០២៣ ថា លោកមិនហ៊ាននិយាយគ្នាតាមទូរសព្ទទេ ព្រោះខ្លាចមានការលួចថតសំឡេងគឺលោកជ្រើសរើសការទំនាក់ទំនងតាម អ៊ីនធើណេត។

លោក ហ៊ុន សែន៖ «*អាស្មាតហ្វូតហ្នឹងជំនាញត្រូវរៀនមុនគេគឺទំនាក់ទំនងតែម្ដង។ ហើយខ្ញុំ សូមប្រាប់ឱ្យហើយអ្នកទូរសព្ទមកខ្ញុំគឺខ្ញុំអត់ទទួលទេ។ ប៉ុន្តែបើគេមកតាម WhatUp Line Telegram Viber Signal អាហ្នឹងខ្ញុំទទួល។ ឱ្យតែមកតាមអ៊ីនធើណេតខ្ញុំទទួល ប៉ុន្តែបើតាមហ្វូនខ្ញុំអត់ទទួលទេ។ ខ្ញុំអត់និយាយទេព្រោះសំឡេងខ្ញុំត្រូវគេចាប់*»។



*ប្រជាពលរដ្ឋកំពុងធ្វើដំណើរឆ្លងកាត់មុខក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ តាមបណ្តោយមហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ។ រូបថតនៅថ្ងៃទី៦ ខែមេសា ឆ្នាំ២០២៣។ អាន វិចិត្រ/ ខេមបូចា*

របាយការណ៍របស់ស្ថាប័នទិន្នន័យ Statista បង្ហាញថា គិតត្រឹមឆ្នាំ២០២១ ក្នុងចំណោមពលរដ្ឋប្រមាណ១៦លាននាក់មានចំនួនលេខទូរសព្ទប្រើប្រាស់ជិត២០លាន(១៩,៩លានលេខ)គឺពលរដ្ឋខ្លះប្រើលេខទូរសព្ទលើសពី១។

ក្នុងរបាយការណ៍របស់អង្គការសង្គមស៊ីវិលក្នុងស្រុកដាក់ទៅអង្គការសហប្រជាជាតិកាលពីឆ្នាំ២០១៨ បញ្ហាលួចថតសំឡេងសន្ទនាជាលក្ខណៈឯកជនក៏ត្រូវបានដាក់បញ្ចូលជាចំណុចមួយក្នុងចំណោមក្តីបារម្ភពីការរំលោភសិទ្ធិមនុស្សផ្សេងៗទៀតដែរ។

នាយិកាមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាលោកស្រី ចក់ សុភាព ចាត់ទុកការលួចស្តាប់ការសន្ទនាតាមទូរសព្ទនេះខុសទាំងច្បាប់ និងបំពានសិទ្ធិឯកជនអ្នកប្រើប្រា

ស់។ ទន្ទឹមនឹងការជំរុញឱ្យស្ថាប័នរដ្ឋ និងក្រុមហ៊ុនទូរសព្ទពង្រឹងសុវត្ថិភាពដល់អ្នកប្រើប្រាស់ លោកស្រី ចក់ សុភាព ក៏រំឭកអ្នកប្រើប្រាស់ខ្លួនឯងឱ្យមានការប្រុងប្រយ័ត្នដែរ។

លោកស្រី ចក់ សុភាព ថ្លែងថា៖ *«រដ្ឋត្រូវធានាប្រព័ន្ធទូរគមនាគមន៍ហើយក្រុមហ៊ុនទៀតសោតក៏ត្រូវធានាសុវត្ថិភាពដល់អតិថិជន ហើយអតិថិជនខ្លួនឯងអ្នកប្រើប្រាស់ហ្នឹងមានការប្រុងប្រយ័ត្នក្នុងការប្រើប្រាស់បច្ចេកវិទ្យានៅសម័យបច្ចុប្បន្ន»*។

មេធាវី សុក សំអឿន ពន្យល់ថា សមត្ថកិច្ចនគរបាលដែលអ្នកធ្វើការតំណាងឱ្យរដ្ឋាភិបាលជាអ្នកទប់ស្កាត់បទល្មើសលួចថតសំឡេងនេះ។ លោកបន្តថា បើនគរបាលអសកម្មនោះធ្វើឱ្យពលរដ្ឋឈានដល់មិនទុកចិត្តរដ្ឋាភិបាល។

លោក សុក សំអឿន បានបញ្ជាក់ថា៖ «*ប៉ូលិស និងរដ្ឋាភិបាលហ្នឹងហើយជាអ្នកទប់ស្កាត់។ បើរដ្ឋាភិបាលមិនទប់ស្កាត់ ប្រជាពលរដ្ឋមានការភ័យខ្លាច ហើយប្រជាពលរដ្ឋអាចមិនទុកចិត្តរដ្ឋាភិបាលទៅវិញ [អ៊ី]ចឹងរដ្ឋាភិបាលត្រូវគិតគូរឿងហ្នឹងឡើងវិញ*»។

អ្នកជំនាញផ្នែកបច្ចេកវិទ្យាឌីជីថលនៃអង្គការសង់ត្រាល់ លោក ម៉េង អ៊ីដែត លើកទឹកចិត្តឱ្យសាធារណជនប្រើប្រាស់អ៊ីនធើណេតតាមកម្មវិធីមួយចំនួនដែលមានសុវត្ថិភាពក្នុងការទំនាក់ទំនង។

លោក ម៉េង អ៊ីដែត លើកឡើងថា៖ *«បើយើងអាចប្រើប្រាស់នូវកម្មវិធីទំនាក់ទំនងគ្នាបានដូចជា Signal App ឬ WhatsApp app គឺជាប្រការដ៏ល្អបំផុត ព្រោះថាកម្មវិធីទាំង២នេះជាប្រភេទ End-to-end encryption ដែលវាមានសមត្ថភាពបំលែង*

*សារ ក៏ដូចជាសំឡេងសន្ទនារបស់យើងទៅអ្វីផ្សេងមួយទៀតនៅមុនរាល់ពេលបញ្ជូនចេញទៅអ្នកម្ខាងទៀត*»។

អ្នកនាំពាក្យក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ លោក សូ វិសុទ្ធី ហៅទូរសព្ទចូលប្រាប់ឱ្យផ្ញើសំណួរវិញ តែពេលផ្ញើសំណួរទៅប្រមាណ១សប្តាហ៍មកនេះមិនមានការឆ្លើយទេ។ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ លោក ជា វ៉ាន់ដេត និងអ្នកនាំពាក្យដទៃទៀតក៏មិនអាចសុំការបកស្រាយបានទេជុំវិញករណីនេះ។

រដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលនៃប្រទេសបានការពារសិទ្ធិនៃការទំនាក់ទំនងជាលក្ខណៈឯកជន។ មាត្រា៤០នៃរដ្ឋធម្មនុញ្ញ មិនត្រឹមតែការពារពលរដ្ឋកម្ពុជាគ្រប់រូបពីការលបថតសំឡេងនិយាយសន្ទនាគ្នាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធានាការពារអាថ៌កំបាំងនៃការឆ្លើយឆ្លងតាមលិខិត តាមសារទូរលេខ ទូរពុម្ពទូរគមនាគមន៍របស់ពលរដ្ឋទៀតផង។

ចំណែកច្បាប់ស្តីពីទូរគមនាគមន៍បញ្ជាក់យ៉ាងច្បាស់ថា ទាំងអ្នកលបថតសំឡេងគេ ទាំងអ្នកយកសំឡេងលបថតនោះទៅផ្សព្វផ្សាយ ត្រូវមានទោសស្មើគ្នា។ មាត្រា៩៧នៃច្បាប់នេះ ចែងថា ការលបស្តាប់ ឬការលបថតការសន្ទនាដោយការប្រើប្រាស់ប្រព័ន្ធទូរគមនាគមន៍ ដោយបុគ្គលដែលពុំមែនជាភាគីនៃការសន្ទនាត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ខែទៅ១ឆ្នាំ និងទទួលពិន័យជាប្រាក់ពី១សែនរៀលទៅ២លានរៀល។ បញ្ញត្តិកថាខណ្ឌទី១ ខាងលើនេះ មិនត្រូវយកមកអនុវត្តទេក្នុងករណីដែលការស្តាប់ ឬការថតការសន្ទនានោះ ធ្វើឡើងដោយមានការយល់ព្រមពីបុគ្គលដែលមានការពាក់ព័ន្ធ ឬដោយមានការអនុញ្ញាតពីអាជ្ញាធរជម្មានរូប៕